# បត្តិទានគាថា   បាលី-ប្រែ

យំ កិញ្ចិ កុសលកម្មំ កត្តព្វំ កិរិយំ មម *អំពើជាកុសលឯណាមួយដែលខ្ញុំគប្បីធ្វើ* កាយេន វាចាមនសា *ដោយទ្វារទាំង៣ គឺកាយ វាចា ចិត្ត* តិទសេ សុគតំ កតំ *អំពើជាកុសលទាំងអស់នោះដែលខ្ញុំបានធ្វើហើយជាកុសលអាច នឹងនាំឱ្យទៅកើតក្នុងស្ថានត្រៃត្រឹង្សស្ថិតបាន* យេ សត្តា សញ្ញិនោ អត្ថិ *សត្វទាំងឡាយឯណា គឺជាមនុស្សឬទេវតាឬព្រហ្ម ដែលជាសត្វមានសញ្ញាក្តី* យេ ច សត្តា អសញ្ញិនោ *សត្វទាំងឡាយឯណាជាអសញ្ញិសត្វ គឺសត្វដែលឥតសញ្ញាក្តី* កតំ បុញ្ញផលំ មយ្ហំ សព្វេ ភាគី ភវន្តុ តេ *សត្វទាំងឡាយទាំងអស់នោះចូរឱ្យបាននូវចំណែកផលនៃបុណ្យ ហើយចូរសោយនូវផលនៃបុណ្យដែលយើងខ្ញុំបានធ្វើ ហើយបានឧទ្ទិសផ្សាយឱ្យទៅនេះចុះ* យេ តំ កតំ សុវិទិតំ ទិន្នំ បុញ្ញផលំ មយា *បុណ្យដែលខ្ញុំបានធ្វើហើយនោះ បើសត្វទាំងឡាយឯណាបានដឹងច្បាស់ហើយ សត្វទាំងឡាយនោះ ចូរឱ្យបានសោយនូវផលនៃបុណ្យ ដែលខ្ញុំបានឧទ្ទិសឱ្យទៅនោះចុះ* យេ ច តត្ថ ន ជានន្តិ *ម្យ៉ាងទៀត បណ្តាអស់សត្វទាំងនោះ បើសត្វទាំងឡាយឯណាមិនបានដឹងនូវបុណ្យដែលខ្ញុំបានធ្វើហើយនោះ* ទេវា គន្ត្វានិ វេទយុំ *សូមទេវតាទាំងឡាយអញ្ជើញទៅឱ្យដំណឹងដល់សត្វទាំងឡាយនោះឱ្យបានដឹងផងថា ជនឯណោះគេបានធ្វើបុណ្យ ហើយគេឧទ្ទិសផ្សាយផលបុណ្យនោះមកដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរអនុមោទនា ត្រេកអរនឹងបុណ្យគេនោះចុះ* សព្វេ លោកម្ហិ យេ សត្តា ជីវន្តាហារហេតុកា *សត្វទាំងឡាយឯណាក្នុងលោកទាំងអស់ ដែលអាស្រ័យនូវអាហារហើយរស់នៅ* មនុញ្ញំ ភោជនំ សព្វេ លភន្តុ មម ចេតសាតិ *សត្វទាំងឡាយទាំងអស់នោះ ចូរឱ្យបាននូវភោជនជាទីគាប់ចិត្ត ដែលសម្រេចដោយបុញ្ញឫទ្ធិ តាមចិត្តដែលខ្ញុំឧទ្ទិស ផ្សាយទៅឱ្យនេះចុះ ។*

(បត្តិទានគាថានេះ សម្រាប់សូត្របានក្នុងទីទាំងពួង ក្នុងកាលដែលបានធ្វើកុសលអ្វីមួយហើយស្រេច )



កស្រង់និងចងក្រងដោយខ្ញុំបាទ **ទ៉ាន់ អ៊ុង** អាចារ្យទី១សម្រាប់វត្តធម្មារាម ក្រុងស្តុកតុន រដ្ឋកាលីហ្វរនីញ៉ាព.ស.២៥៤៣
វាយចម្លងដាក់គេហទំព័រវត្ត ដោយខ្ញុំព្រះករុណាខ្ញុំបាទ **អ៊ិន លី** ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១២

វត្តធម្មារាម